អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ ល្បែងបង្កើតខ្លុយខ្យល់បែបបទេស

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖ ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

**បុរេគណិត** ៖ រង្វាស់រង្វល់៖ បញ្ញត្តិស្តីពីរង្វាស់រង្វល់

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ វិជ្ជាសម្ពទា៖ ប្រាប់បានពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងអ្វីមួយ។

បំណិនសម្បទា៖កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិង សម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

ចរិយាសម្បទា៖ មានអំណត់ តស៊ូព្យាយាមនិងសប្បាយរីករាយក្នុងពេលលេងអ្វីមួយ ប្រកបដោយភាពជោគជ័យ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

ចរិយាសម្បទា៖ ស្រឡាញ់ចូលចិត្ត បទភ្លេងនិងចម្រៀង។

**បុរេគណិត** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីបញ្ញត្តិខ្ពស់និងទាប វែងនិងខ្លី។

បំណិនសម្បទា៖ ប្រៀបធៀបខ្ពស់និងទាប វែងនិងខ្លី។

ចរិយាសម្បទា៖ សហការ អំណត់ ឧស្សាព្យាយាមនិងប្រុងប្រយ័ត្នក្នុងការវាស់។ និងប្រៀបធៀប

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន។

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង ។

ចរិយាសម្បទា៖ មានបង្រុងប្រយ័ត្នក្នុងការស្តាប់សូរសំឡេងនិងចូលចិត្ត។

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ទុយោរមួយចំនួន ស្កុត ហ្វឹត បន្ទាត់ក្រិត កន្ត្រៃ

**ការរៀបចំ** ៖ រៀបចំសម្ភារនិងផលិតខ្លុយមួយសម្រាប់បង្ហាញទៅកាន់កុមារមុននឹងចាប់ឱ្យកុមារធ្វើនិងលេងខ្លុយខ្យល់។

**សេចក្តីណែនាំ** ៖

1. ដំបូងសួរកុមារថាធ្លាប់ស្គាល់ខ្លុយអត់? កុមារថាស្គាល់ ឬមិនស្គាល់។ បើមិនស្គាល់ ប្រាប់កុមារបន្ថែមទៀត។
2. ប្រាប់កុមារបន្ថែមទៀតថាថ្ងៃនេះយើងនឹងនាំគ្នាបង្កើតខ្លុយខ្យល់បទេសមួយសម្រាប់លេងជាមួយគ្នាស្របពេលហ្នឹងដែរ គ្រូបង្ហាញខ្លុយខ្យល់ដែលបានធ្វើរួចនេះទៅកាន់កុមារព្រមទាំងផ្លុំលេងឱ្យកុមារស្តាប់ផងដែរ។
3. កូនៗចង់លេងអត់? ចង់ចេះបង្កើតអត់? ចង់ៗៗ អ៊ីចឹង តស់ បង្កើតវាទាំងអស់គ្នាណា។
4. ប្រាប់កុមារពីរបៀបក្នុងការបង្កើតទៅកុមារជាមុនសិន៖
   - ☐ យកទុយោរទាំងអស់ដែលបានត្រៀមមកកាត់ម្តងមួយ ពីវែងបំផុតទៅខ្លីបំផុត ដោយប្រើបន្ទាត់ដែលមានក្រិតវាស់មុននឹងកាត់វា។
   - ☐ បន្ទាប់មក យកទុយោរទាំងអស់ដែលបានកាត់រួច មកតម្រៀបជាប់គ្នាពីខ្លីទៅវែង ឬពីវែងទៅខ្លី។
   - ☐ តម្រឹមវាឱ្យបានស្មើល្អ បន្ទាប់ប្រើស្កុតបិទឱ្យបានជាប់មាំល្អ (បិទខាងលើ១ និងខាងក្រោម១) ជាការស្រេច។
   - ☐ ចុងក្រោយ អ្នកអាចនាំកុមារផ្លុំខ្លុយខ្យល់លេងបានយ៉ាងសប្បាយជាមួយគ្នាផងដែរ។
5. នៅពេលដែលបង្កើតរួច រៀបចំសម្ភារ សម្អាតជាការស្រេច។